ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការរៀបចំអបអរសាទរខួបលើកទី១៣៣ ទិវាពលកម្មអន្តរជាតិ ១ ឧសភា ឆ្នាំ២០១៩

អនុលោមទៅតាមសារាចរលេខ០៤ សរណន ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ ស្តីពី ការរៀបចំខួប ១០០ឆ្នាំ របស់អង្គការអន្តរជាតិខាងការងារ ខួប៥០ឆ្នាំនៃសមាជិកភាពរបស់កម្ពុជានៅអង្គការអន្តរជាតិខាងការងារ និងខួបអនុស្សាវរីយ៍លើកទី១៣៣ ទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៩ ក្រោមប្រធានបទ **"កិច្ចគាំពារសង្គមដើម្បីផលិតភាព"** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារជន កម្មករនិយោជិត និយោជក អង្គការវិជ្ជាជីវៈ មេត្តាជ្រាបថា គិតត្រឹមវេលាម៉ោង ១១ ព្រឹកថ្ងៃទី១ ឧសភា ឆ្នាំ២០១៩ នេះ៖

- គ្រប់រោងចក្រ សហគ្រាស គ្រឹះស្ថានចំនួន ១២.៩៥០ ដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមប្រារព្ធទិវាពលកម្មអន្តរជាតិ ១ ឧសភា
- មានរោងចក្រសហគ្រាសធំៗ ទូទាំងប្រទេស ចំនួនប្រមាណ១.២៨៧ ដែលមានកម្មករនិយោជិតប្រមាណ ៧៩ម៉ឺននាក់ បានរៀបចំពិធីកំសាន្តសប្បាយ លេងល្បែងប្រជាប្រិយ ពិសារបាយ សាមគ្គី និងចាប់រង្វាន់ ដើម្បីអបអរសាទរ ចូលឆ្នាំថ្មីប្រពៃណីជាតិផង និងទិវាពលកម្មអន្តរជាតិ ១ ឧសភា ផង
- គ្រប់រាជធានី ខេត្ត ក៏បានចាត់តាំង ប្រារព្ធខួបលើកទី ១៣៣ ទិវាពលកម្មអន្តរជាតិនេះ ទៅតាមទីកន្លែង និងកម្មវិធីរៀងៗខ្លួន ប្រកបដោយបរិយាកាសរីករាយ ស្និទស្នាល
- នាព្រឹកថ្ងៃទី២៤ ខែមេសា នេះ នៅទីស្តីការក្រសួង ក៏មានការប្រារព្ធខួបលើកទី១៣៣ ទិវាពលកម្មអន្តរជាតិ ១ ឧសភា ជាលក្ខណៈត្រីភាគី ដោយមានការចូលរួមពីតំណាង កម្មករនិយោជិត សហជីពគ្រប់លំដាប់ថ្នាក់ សមាគមនិយោជក និងអង្គការវិជ្ជាជីវៈ ចំនួន ៥៥៣នាក់ ប្រកបដោយបរិយាកាសរីករាយ យោគយល់ និងទទួលបានផ្លែផ្កា គួរជាទីមោទនៈ។
- នាល្ងាច ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៩ នេះ ដោយមានការចូលរួមពីសហព័ន្ធសហភាពយុវជនកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា អគ្គនាយកដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ន និងដៃគូពាក់ព័ន្ធនានា ក្រសួងនឹងរៀបចំកម្មវិធីប្រកួតផ្តាច់ព្រាត់**"សម្រស់ឯកវាយនភណ្ឌឆ្នាំ២០១៩"** នេះ ដោយមានការផ្សាយផ្ទាល់តាមកញ្ចក់ទូរទស្សន៍បាយ័ន ផងដែរ។

ជារួម ការប្រារព្ធពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣៣ ទិវាពលកម្មអន្តរជាតិ ១ ឧសភា ឆ្នាំនេះ បានប្រព្រឹត្តទៅកាន់តែសកម្ម និងផុសផុល ក្រោមបរិយាកាសរីករាយ ស្និទស្នាលជាងឆ្នាំមុនៗ គឺដោយសារកម្ពុជាមានសុខសន្តិភាព ស្ថិរភាព រក្សាបាននូវកំណើនសេដ្ឋកិច្ចខ្លាំង មានទំនាក់ទំនងវិជ្ជាជីវៈ រវាងកម្មករនិយោជិត និងនិយោជកកាន់តែល្អ និងមានយន្តការត្រីភាគីកាន់តែល្អប្រសើរក្នុងការជជែកគ្រប់គ្រងបញ្ហាប្រឈម ដោយឈរលើគោលការណ៍នីតិរដ្ឋ និងបច្ចេកទេស ដោយមានការសហការបច្ចេកទេស ពីអង្គការអន្តរជាតិខាងការងារ។

សេចក្តីដូចមានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសកម្មករនិយោជិត និយោជក អង្គការវិជ្ជាជីវៈទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ពុធ ១២រោច ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ២០១៩